**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**
**លេខ** ...............៣៤១.............ក.ប/ប្រ.ក

# ប្រកាស
# ស្តីពី
# ការកំណត់ និងការគ្រប់គ្រងសហគ្រាស គ្រឹះស្ថាននៅរាជធានីភ្នំពេញ

## រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការបញ្ចប់ និងតែងតាំងសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខនស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញព្រះរាជក្រមលេខជស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការងារ
- យោងអនុក្រឹត្យលេខ ២៨៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

## សម្រេច

**ប្រការ១ .–**

ប្រកាសនេះមានគោលបំណងពង្រឹងប្រសិទ្ធភាពក្នុងការអនុវត្តច្បាប់ស្តីពីការងារ និងលើកកម្ពស់លក្ខខណ្ឌការងារ អនាម័យ និងសន្តិសុខការងារ និងទំនាក់ទំនងវិជ្ជាជីវៈឱ្យកាន់តែល្អប្រសើរ។



អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣)៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩

**ប្រការ២ ._**

ប្រកាសនេះមានគោលដៅ កំណត់ដែនក្នុងការគ្រប់គ្រងសហគ្រាស គ្រឹះស្ថាន ក្នុងរាជធានីភ្នំពេញ រវាងអង្គភាពថ្នាក់ជាតិនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានីភ្នំពេញ។

**ប្រការ៣ ._**

សហគ្រាស គ្រឹះស្ថានក្នុងរាជធានីភ្នំពេញ ដូចមានក្នុងបញ្ជីឈ្មោះសហគ្រាស គ្រឹះស្ថានដែលជាឧបសម្ព័ន្ធនៃប្រកាសនេះ ត្រូវស្ថិតក្នុងសមត្ថកិច្ចរបស់អង្គភាពថ្នាក់ជាតិនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

**ប្រការ៤ ._**

សហគ្រាស គ្រឹះស្ថានទាំងឡាយណា ដែលមិនបានកំណត់ក្នុងបញ្ជីរាយនាមសហគ្រាស គ្រឹះស្ថានដូចមាននៅក្នុងឧបសម្ព័ន្ធនៃប្រកាសនេះ ត្រូវស្ថិតក្រោមការគ្រប់គ្រងរបស់មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានីភ្នំពេញ។

**ប្រការ៥ ._**

សហគ្រាស គ្រឹះស្ថានទាំងឡាយណា ដែលបានបំពេញបែបបទស្តីពីសហគ្រាស គ្រឹះស្ថានរួចហើយ នៅតែមានសុពលភាពប្រើប្រាស់បែបបទនោះ វៀរលែងតែមានការផ្លាស់ប្តូរនាមករណ៍របស់សហគ្រាស គ្រឹះស្ថាន។

**ប្រការ៦ ._**

ប្រភេទសហគ្រាស គ្រឹះស្ថាន ដែលទើបបើកដំណើរការថ្មី ដូចខាងក្រោម ត្រូវស្ថិតក្រោមការគ្រប់គ្រងរបស់អង្គភាពថ្នាក់ជាតិនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ៖

១. វិស័យវាយនភ័ណ្ឌ កាត់ដេរ និងផលិតស្បែកជើងដែលបម្រើឱ្យការនាំចេញ

២. ឧស្សាហកម្ម

៣. ក្រុមហ៊ុននាំពលករទៅធ្វើការនៅក្រៅប្រទេស

៤. អង្គការក្រៅរដ្ឋាភិបាល

៥. ក្រុមហ៊ុនសំណង់

៦. សណ្ឋាគារ

៧. ធនាគារ

៨. អាកាសចរណ៍

៩. នាវាចរណ៍។

**ប្រការ៧ ._**

ប្រកាសលេខ ១៨៥ កប/ប្រក ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០០៨ ស្តីពីការកំណត់ការគ្រប់គ្រងកម្មករនិយោជិតនៅតាមសហគ្រាស គ្រឹះស្ថានធុនតូច និងមធ្យមនៅរាជធានីភ្នំពេញ និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៨ .-**

នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានការងារ និងអង្គភាពពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

*រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ សីហា ឆ្នាំ២០១៦*

**រដ្ឋមន្ត្រី**

**អ៊ិត សំហេង**

**កន្លែងទទួល៖**

-ទីស្ដីការគណៈរដ្ឋមន្ត្រី
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្ដេចតេជោនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្ដេច ឯកឧត្ដម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
-សមាគមនិយោជក
"ដើម្បីជូនជ្រាប"
-ដូចប្រការ ៨
-គ្រប់អង្គភាពក្រោមឱវាទក្រសួង
"ដើម្បីអនុវត្ត"
-ឯកសារ-កាលប្បវត្តិ